ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៩៤...សជណ

ជំរាបជូន

ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត- ក្រុង

ដោយសង្កេតឃើញថា មេរោគអេដស៍បាននិងកំពុងចម្លងរាលដាលនៅក្នុងប្រទេសយើងយ៉ាងខ្លាំងក្លា ។ ការខិតខំអប់រំផ្សព្វផ្សាយអោយប្រជាជន មហាជនបានយល់ដឹងអំពីការឆ្លងនៃជំងឺអេដស៍ គឺជាប្រការដ៏សំខាន់បំផុត ក៏កំពុងបានប្រព្រឹត្តទៅយ៉ាងសកម្ម ប៉ុន្តែនៅទីកន្លែងខ្លះ និងមជ្ឈដ្ឋានខ្លះមិនទាន់ទទួលបានប្រសិទ្ធភាពនៅឡើយ ។ ជាមួយគ្នានេះ យើងបានជំរុញអោយមានការប្រើប្រាស់ស្រោមអនាម័យអោយបាន ១០០ ភាគរយ ហើយយើងក៏អនុវត្តជាកពិសោធន៍ប្រកបដោយលទ្ធផលល្អ ដូចជានៅក្រុងព្រះសីហនុជាដើម ។ រាជរដ្ឋាភិបាលនិងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍យល់ថា វិធានការជំរុញប្រើប្រាស់ស្រោមអនាម័យអោយបាន ១០០ ភាគរយ គឺជាវិធានការមានប្រសិទ្ធភាពមួយដែលយើងបាន និងកំពុងស្វែងរកមូលដ្ឋានសំភារៈថវិកាបំរើអោយកម្មវិធីនេះ ។

រាជរដ្ឋាភិបាលសូមជំរាបជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត- ក្រុងទាំងអស់ប្រមូលផ្តុំនូវសក្តានុពលទាំងឡាយក្នុងមូលដ្ឋានរបស់ខ្លួនជំរុញការប្រើប្រាស់ស្រោមអនាម័យអោយបាន ១០០ ភាគរយ ។

ដូច្នេះការអប់រំផ្សព្វផ្សាយប្រយុទ្ធនឹងជំងឺអេដស៍ គឺជាភារកិច្ច និងការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា ហើយបើមូលដ្ឋាន ខេត្ត- ក្រុងណា នៅមានអត្រារាលដាលជំងឺអេដស៍ខ្ពស់នៅឡើយ វាមិនត្រឹមតែជាការធ្វើអោយចុះខ្សោយនូវមូលដ្ឋាននោះប៉ុណ្ណោះទេ គឺធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គម និងសេដ្ឋកិច្ចជាតិយើងទាំងមូលផងដែរ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត- ក្រុង ចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើអោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង និងស្ថាប័ន
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកសារ- កាលប្បវត្តិ

លេខៈ ១៥៣ អ.ជ.ប.ជ.អ
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
-ដើម្បីអនុវត្តន៍-
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦
ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង_មូលី